ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០៨៩/១៧-ហ្គាវ័ន្ត អ៊ីតែរីល ខូអិលធីឌី
កាលបរិច្ឆេទនៃសេចក្តីបង្គាប់៖ ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **វ៉ែន ពៅ**
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន ហ្គាវ័ន្ត អ៊ីតែរីល ខូអិលធីឌី**
អាសយដ្ឋាន ៖ ភូមិព្រែកសំរោង សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល
ទូរស័ព្ទ ៖ ០១២ ៥២២ ២៦៦ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជកចូលរួមប្រជុំមុនសវនាការ ៖

| | |
|---|---|
| ១- លោកស្រី CHA KYEONG HEE | នាយកក្រុមហ៊ុន |
| ២- លោកស្រី ហង់ វណ្ណលេន | អ្នករៀបចំឯកសារ |
| ៣- លោក ឡុង ប៊ាង | មន្ត្រីជាន់ខ្ពស់ GMAC |

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖ **ភាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ហ្គាវ័ន្ត អ៊ីតែរីល ខូអិលធីឌី**
អាសយដ្ឋាន ៖ ភូមិព្រែកសំរោង សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល
ទូរស័ព្ទ ៖ ០៨៦ ៦៤៦ ៦៥៦ ទូរសារ ៖ គ្មាន
តំណាងកម្មករនិយោជិតចូលរួមប្រជុំមុនសវនាការ ៖



ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥.២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Toul Kork, Phnom Penh + Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org + Website: www.arbitrationcouncil.org

១- លោក ស៊ាង យ៉ូត	មន្ត្រីសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា
២- លោក វ៉ាន់ បូរ៉ា	ប្រធានសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរប្រចាំក្រុមហ៊ុន
៣- លោក ប្រាក់ ចាន់ថន	អនុប្រធានសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរប្រចាំក្រុមហ៊ុន
៤- លោក គ្រិស ចន្ថា	លេខាធិការសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរប្រចាំក្រុមហ៊ុន
៥- លោកស្រី សាន់ សុខន	សកម្មជន
៦- លោកស្រី ថូ ណៃយៀប	សកម្មជន
៧- លោកស្រី សែ វ៉ា	កម្មករ
៨- លោកស្រី អៀង ចាន់មុំ	កម្មករ
៩- លោកស្រី ញ៉ែម សារ៉េត	កម្មករ
១០- លោកស្រី ម៉ី សុខគង់	កម្មករ
១១- លោកស្រី ហួ សុខលីន	កម្មករ

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

- ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុន នៅពេលកូដកម្មក្នុងខែវិច្ឆិកា ឆ្នាំ២០១៧ សុំរក្សាប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំផ្សេងៗ ចំនួន ០៧ ថ្ងៃ នៅដដែល។ ក្រុមហ៊ុនមិនឯកភាព គឺរក្សាប្រាក់ឈ្នួលជូន ចំនួន ០៣ ថ្ងៃកន្លះ នៅដដែល រីឯចំនួន ០៣ ថ្ងៃកន្លះទៀត កាត់កងជួសថ្ងៃឈប់សម្រាកប្រចាំឆ្នាំ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃ ប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ២០៨ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៧ (អាណត្តិទី១៥)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ហ្គាវ័ន្ត អ៊ីភែរីល ខូអិលធីឌី លេខ ០៩៤/១៧ ក.ប/កណ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៧។

THE ARBITRATION COUNCIL

**សវនាការ និង សន្ទេបនីតិវិធី**

**ទីកន្លែងជួបប្រជុំមុនសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល "ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៩៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់២, ខណ្ឌទួលគោក, ភ្នំពេញ" ។

**កាលបរិច្ឆេទប្រជុំមុនសវនាការ ៖** ថ្ងៃចន្ទ ៨កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
ត្រូវនឹងថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧ វេលាម៉ោង ០៨ និង ០០ នាទី ព្រឹក ។

**បញ្ហានីតិវិធី៖**

នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៧ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានទទួលពាក្យបណ្តឹងរបស់កម្មករនិយោជិតនៃក្រុមហ៊ុន ហ្គាវ័ន្ត អ៊ីភែរីល ខូអិលធីឌី ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៧។ បន្ទាប់ពីទទួលពាក្យបណ្តឹងនេះមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយវិវាទការងារនេះ និងធ្វើការផ្សះផ្សាវិវាទ ចំនួន ១ ចំណុច នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៧ ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ។ ចំណុចមិនសះជា ចំនួន ១ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៧ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម នៅក្រុមហ៊ុន ហ្គាវ័ន្ត អ៊ីភែរីល ខូលអិលធីឌី លេខ ០៤៤/១៧ ក.ប/កណ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៧។ នៅមុនពេលក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើង លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានទទួលលិខិតមួយច្បាប់ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧ របស់ក្រុមហ៊ុន ហ្គាវ័ន្ត អ៊ីភែរីល ខូអិលធីឌី ដែលមានកម្មវត្ថុស្នើសុំឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលចេញសេចក្តីបញ្ជា ដើម្បីផ្អាកការធ្វើកូដកម្មរបស់កម្មករនិយោជិតនៅក្រុមហ៊ុន Gawon (ហ្គាវ័ន្ត)។ ហេតុនេះ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៧ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជា លេខ ០០៦/១៧ កបអ. ឱ្យផ្អាកជាបន្ទាន់ នូវការធ្វើកូដកម្មរបស់កម្មករនិយោជិតនៃក្រុមហ៊ុន ហ្គាវ័ន្ត អ៊ីភែរីល ខូអិលធីឌី រហូតដល់នីតិវិធីនៃអាជ្ញាកណ្តាលត្រូវបានបញ្ចប់សព្វគ្រប់តាមនីតិវិធីច្បាប់ ហើយកូដករទាំងអស់ ត្រូវត្រឡប់ចូលធ្វើការវិញ ចាប់ពីព្រឹកថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៧ តទៅ តាមវេនរបស់ខ្លួន។

បន្ទាប់ពីចេញសេចក្តីបញ្ជានេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលដំណឹងពីភាគីនិយោជក និងកម្មករនិយោ-ជិត (កម្មករនិយោជិត វ៉ាន់ បូរ៉ា ដែលមានឈ្មោះនៅក្នុងលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិត) តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលថា នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៧ កម្មករនិយោជិតមិនបានត្រឡប់ចូលធ្វើការតាមសេចក្តីបញ្ជានោះទេ ហើយនៅតែបន្តធ្វើកូដកម្មដដែល។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញភាគីពាក់ព័ន្ធមកសាកសួរព័ត៌មានបន្ថែម ក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាលនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧ វេលាម៉ោង ៨ និង ០០ នាទី ព្រឹក។ នៅក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាល ភាគីនិយោជក និងភាគីកម្មករនិយោជិត មានវត្តមាន តាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ប៉ុន្តែ ភាគីកម្មករនិយោជិត បានបដិសេធថា ពួកគាត់មិនបានដឹង និងមិនមានកម្មករនិយោជិតណាម្នាក់នៅក្នុងក្រុមហ៊ុន ហ្គាវ័ន្ត អ៊ីភែរីល បានផ្តិតមេដៃប្រគល់សិទ្ធិឱ្យពួកគាត់ធ្វើជាតំណាងក្នុងការដោះស្រាយវិវាទក្នុងសំណុំរឿងនេះទេ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា យោងតាមលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម របស់មន្ទីរការងារ ខេត្តកណ្តាល លេខ ០១២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៧ មានឈ្មោះកម្មករនិយោជិត ចំនួន ៥ នាក់ គឺ ១. រ៉ាន់ បូរ៉ា ២. ប្រាក់ ចាន់ថន ៣. គ្រិស ចន្ថា ៤. សាន់ សុខន និង ៥. ថូ ណៃយៀប ដែលជាអ្នកតំណាងភាគីកម្មករនិយោជិតក្នុងក្រុមហ៊ុន ហ្គាវ័ន្ត អីភែរីល ខូអិលធីឌី ដើម្បីចូលរួមដោះស្រាយវិវាទក្នុងសំណុំរឿងនេះ។ នៅក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាល កម្មករនិយោជិតទាំង ៥ នាក់ ដែលមានឈ្មោះនៅក្នុងលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតខាងលើ រួមទាំងកម្មករនិយោជិត ចំនួន ៥ នាក់ផ្សេងទៀត គឺ ១. សែ រ៉ា ២. អៀង ចាន់មុំ ៣. ញ៉ែម សារ៉េត ៤. មុី សុគង់ និង ៥. ហូ សុខលីន ក៏មានវត្តមាននៅក្នុងកិច្ចប្រជុំនេះដែរ។ ដោយឡែក កម្មករនិយោជិតដែលមានវត្តមានទាំងនោះ បានជំទាស់នៅក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាលថា ពួកគាត់មិនបានដឹងពីសំណុំរឿងលេខ ០៤៩/១៧-ហ្គាវ័ន្ត អីភែរីល ខូអិលធីឌី នេះ និងមិនបានដឹងពីលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតខាងលើនោះទេ។ ម្យ៉ាងទៀត នៅក្នុងសំណុំរឿងនេះ ក៏មិនមានកម្មករនិយោជិតណាម្នាក់នៅក្នុងក្រុមហ៊ុន ហ្គាវ័ន្ត អីភែរីល បានផ្តិតមេដៃប្រគល់សិទ្ធិឱ្យពួកគាត់ធ្វើជាតំណាងក្នុងការដោះស្រាយវិវាទក្នុងសំណុំរឿងនេះទេ។

លើសពីនេះ កម្មករនិយោជិតដែលមានឈ្មោះនៅក្នុងលិខិតបញ្ជាក់អ្នកតំណាង និងកម្មករនិយោជិតផ្សេងទៀតដែលមានវត្តមានខាងលើ បានបញ្ជាក់បន្ថែមទៀតថា ពួកគាត់បានអញ្ជើញមកក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីចូលរួមក្នុងការដោះស្រាយវិវាទការងាររួម នៅក្នុងសំណុំរឿងផ្សេងមួយទៀត លេខ ០៤៧/១៧ នៅក្រុមប្រឹក្សាអាជ្ញាកណ្តាលប៉ុណ្ណោះ មិនមែនចូលរួមដោះស្រាយក្នុងសំណុំរឿងនេះទេ។

ទោះជាយ៉ាងណាក៏ដោយ ភាគីនិយោជកដែលមានវត្តមាននៅក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាល នៅព្រឹកថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧ បានបញ្ជាក់ថា នៅព្រឹកនេះ មានកម្មករនិយោជិត ចំនួន ៦៥២ នាក់ នៃកម្មករនិយោជិតសរុប ចំនួន ៩២០ នាក់ បានស្កេនមេដៃចូលទៅក្នុងក្រុមហ៊ុន ប៉ុន្តែ កម្មករនិយោជិតមិនបានធ្វើការនោះទេ បើទោះជាក្រុមហ៊ុនមានការងារឱ្យពួកគាត់ធ្វើក៏ដោយ។ ភាគីនិយោជកចាត់ទុកទង្វើរបស់កម្មករនិយោជិត ដែលគ្រាន់តែស្កេនមេដៃចូលក្នុងក្រុមហ៊ុនហើយមិនព្រមធ្វើការ ថាមិនគោរពទៅតាមសេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលឱ្យផ្អាកជាបន្ទាន់នូវការធ្វើកូដកម្មនោះទេ។ ម្យ៉ាងទៀត នៅរសៀលថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧ ដដែលនោះ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានទាក់ទងទៅភាគីនិយោជកម្តងទៀត ដើម្បីសាកសួរពីបញ្ហាកូដកម្ម ហើយភាគីនិយោជកបានបញ្ជាក់ថា មានកម្មករនិយោជិតចំនួន ៧០៣ នាក់ បានស្កេនមេដៃចូលក្នុងក្រុមហ៊ុន ប៉ុន្តែ មានតែកម្មករនិយោជិត ចំនួន ១៤៤ នាក់ប៉ុណ្ណោះ បានធ្វើការ ចំណែកឯកម្មករនិយោជិតដទៃទៀត នៅតែមិនព្រមធ្វើការដដែល ដោយពួកគាត់នាំគ្នាអង្គុយលេង។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណា ដូចខាងក្រោម ៖

**តស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន**

**ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៧ របស់នាយកក្រុមហ៊ុន ហ្គាវ័ន្ត អ៊ីភៃរីល ខូអិលធីឌី ប្រគល់សិទ្ធិជូន លោក ឡុង ហ៊ាង ។

២- លិខិតចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧ របស់ក្រុមហ៊ុន ហ្គាវ័ន្ត អ៊ីភៃរីល ខូអិលធីឌី គោរពជូន ក្រុមប្រឹក្សា-អាជ្ញាកណ្តាល ស្តីពីសំណើសុំចេញសេចក្តីបញ្ជា ដើម្បីផ្អាកការធ្វើកូដកម្មរបស់កម្មករនិយោជិត នៅក្រុមហ៊ុន Gawon ។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖ គ្មាន

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ហ្គាវ័ន្ត អ៊ីភៃរីល ខូអិលធីឌី លេខ ០៤៤/១៧ ក.ប/កណ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧ ។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ហ្គាវ័ន្ត អ៊ីភៃរីល ខូអិលធីឌី ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៧ ។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៅក្រុមហ៊ុន ហ្គាវ័ន្ត អ៊ីភៃរីល ខូអិលធីឌី លេខ ០១២ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៧ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល ។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជិតចូលរួមជ្រើសរើសអាជ្ញាកណ្តាល លេខ ៣៣៦ កប/អក/វក/លកអ. ចុះថ្ងៃចន្ទ ១កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៧ ។

២- កំណត់ហេតុស្តីពីការចាប់ឆ្នោតជ្រើសរើសអាជ្ញាកណ្តាលពីបញ្ជីឈ្មោះអាជ្ញាកណ្តាល ស្នើដោយសហជីព កម្មករនិយោជិត ចុះថ្ងៃពុធ ៣កើត ខែបុស្ស ឆ្នាំរកា ព.ស២៥៦១ ត្រូវនឹងថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៧ ។

៣- សេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០០៦/១៧ កបអ. ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ ២០១៧ ។

៤- លិខិតអញ្ជើញភាគីនិយោជកចូលរួមផ្តល់ព័ត៌មាន លេខ ៣៤៨ កប/អក/វក/លកអ. ចុះថ្ងៃសុក្រ ៥កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៧ ។

៥- លិខិតអញ្ជើញភាគីនិយោជិតចូលរួមផ្តល់ព័ត៌មាន លេខ ៣៤៩ កប/អក/វក/លកអ. ចុះថ្ងៃសុក្រ ៥កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៧ ។

**អង្គហេតុ ៖**

មិនមានការរកឃើញអង្គហេតុ ទាក់ទងទៅនឹងចំណុចបញ្ហាវិវាទនៅក្នុងរបាយការណ៍មិនសះជា ដែលមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដោយសារក្រុមប្រឹក្សា-អាជ្ញាកណ្តាលមិនបានដំណើរការសវនាការ ។

**ហេតុផលនៃសេចក្តីសម្រេច ÷**

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើត្រូវបន្តនីតិវិធីអាជ្ញាកណ្តាលដែរ ឬទេ?

ប្រការ ២០ នៃប្រកាសលេខ ០៩៩ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលចែងថា៖ "*ក្នុងអំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ភាគីវិវាទទាំងឡាយត្រូវផ្អាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ (ដូចមានចែងក្នុងមាត្រា ៣១៨ នៃច្បាប់ស្តីពីការងារ) ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ។ ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយ ដែលក្រុមអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម* "។

យោងតាមប្រការ ២០ នៃប្រកាសលេខ ០៩៩ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីវិវាទត្រូវផ្អាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ នៅក្នុងដំណើការអាជ្ញាកណ្តាល។

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយប្រការនេះថា ក្រុមប្រឹក្សាអាជ្ញាកណ្តាល នឹងមិនបន្តដំណើរការអាជ្ញាកណ្តាលទេ នៅពេលណាកម្មករនិយោជិតកំពុងធ្វើកូដកម្ម ឬនិយោជកធ្វើឡុកអៅ។ (*សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៥៩/០៦-សាង វ៉ូ, លេខ ៣៩/០៨-ចុង យ៉ូវ, លេខ ១៣៧/០៩ &១៣៨/០៩-ញ៉ូ ភាញ់, លេខ ១១០/១១-ស៊ីម៉ាញូ, លេខ ១០៤/១៣-សាប្រីណា (ខេមបូឌា), លេខ ១១៩/១៣-ពូ យៀន និងលេខ ០១៩/១៤-ដុងខ្វ ថេកស្តាយ (ខេមបូឌា) និងលេខ ៣២២/១៤-ជីមលី (ខេមបូឌា) ភីធីអ៊ី អិលធីឌី)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ ក៏យល់ស្របទទួលយកហេតុផល និងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងខាងលើដែរ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជា លេខ ០០៦/១៧ កបអ. នៅថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០១៧ ឱ្យកម្មករនិយោជិតបញ្ឈប់កូដកម្ម ហើយចូលធ្វើការធម្មតាវិញ។ ដោយឡែក យោងតាមការអះអាងរបស់ភាគីនិយោជកនៅក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាល និងព័ត៌មានដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលបានពីភាគីនិយោជកនៅក្រោយកិច្ចប្រជុំមុនសវនាការ កម្មករនិយោជិតនៅតែបន្តធ្វើកូដកម្ម ពីព្រោះ ទោះបីជាកម្មករនិយោជិតបានស្តេនមេដៃចូលក្នុងក្រុមហ៊ុនក៏ពិតមែន ប៉ុន្តែ ពួកគាត់មិនបានធ្វើការទេ។ ក្រុមប្រឹក្សាអាជ្ញា-កណ្តាលរកឃើញថា កម្មករនិយោជិត ចំនួន ៥ នាក់ ដែលមានឈ្មោះនៅក្នុងលិខិតបញ្ជាក់អ្នកតំណាងរបស់ភាគីកម្មករនិយោជិតនៅក្នុងក្រុមហ៊ុន ហ្គារ័ន្ត អ៊ីភែរីល ខូអិលធីឌី ព្រមទាំងកម្មករនិយោជិត ចំនួន ៥ នាក់ ផ្សេងទៀតដែលមានវត្តមាននៅក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាល បានបដិសេធថា ពួកគាត់មិនបានដឹងអំពីសំណុំរឿងលេខ ០៤៩/១៧-ហ្គារ័ន្ត អ៊ីភែរីល ខូអិលធីឌី នេះ ហើយក៏មិនទទួលបានការផ្ទេរសិទ្ធិពីកម្មករនិយោជិតណាម្នាក់ក្នុងក្រុមហ៊ុន ហ្គារ័ន្ត អ៊ីភែរីល ខូអិលធីឌី ដើម្បីធ្វើជាតំណាងក្នុងការចូលរួមដោះស្រាយវិវាទនៅក្នុងសំណុំរឿងនេះដែរ។ ក្រៅពីកម្មករនិយោជិតចំនួន ៥ នាក់ ដែលមានឈ្មោះនៅក្នុងលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិត ព្រមទាំងកម្មករនិយោជិត ចំនួន ៥ នាក់ ផ្សេងទៀត ដែលមានវត្តមាននៅក្នុងកិច្ចប្រជុំមុនសវនាការខាងលើ ក្រុមប្រឹក្សា

អាជ្ញាកណ្ដាលរកមិនឃើញថា មានកម្មករនិយោជិតណាម្នាក់ទទួលស្គាល់ខ្លួន ជាភាគីដើមបណ្ដឹង និងផ្ដល់អំណះអំណាងណាមួយ ដែលផ្ទុយនឹងព័ត៌មានរបស់ភាគីនិយោជក ពាក់ព័ន្ធនឹងបញ្ហាកូដកម្មនៅក្នុងសំណុំរឿងនេះឡើយ ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសន្មតថា មិនមានភាគីកម្មករនិយោជិតដែលជាដើមបណ្ដឹងនៅក្នុងសំណុំរឿងនេះ នៅក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្ដាលនោះទេ ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេចទទួលយកអំណះអំណាងរបស់ភាគីនិយោជក ពាក់ព័ន្ធនឹងការបន្តធ្វើកូដកម្មរបស់កម្មករនិយោជិតនៅក្នុងក្រុមហ៊ុននេះ ។

សរុបសេចក្ដីមក ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា កម្មករនិយោជិតនៅក្នុងក្រុមហ៊ុន ហ្គាវ័ន្ត អ៊ីភៃរីល ខូអិលធីឌី នៅតែបន្តធ្វើកូដកម្ម ។

ហេតុនេះ យោងតាមប្រការ ២០ នៃប្រកាសលេខ ០៩៩ ក្រុមប្រឹក្សាអាជ្ញាកណ្ដាល សម្រេចបញ្ចប់ដំណើរការអាជ្ញាកណ្ដាលនៅក្នុងសំណុំរឿងនេះ ។

យោងតាមអង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេចចេញសេចក្ដីបង្គាប់ ដូចតទៅ ៖

## សម្រេច

- បញ្ចប់ដំណើរការអាជ្ញាកណ្ដាលក្នុងសំណុំរឿងលេខ ០៤៩/១៧-ហ្គាវ័ន្ត អ៊ីភៃរីល ខូអិលធីឌី ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

**អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក**

ឈ្មោះ ៖ **អ៊ុំ សុទ្ធី**

ហត្ថលេខា ៖ -----------------------------

**អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត**

ឈ្មោះ ៖ **ទ៉ែន ពៅ**

ហត្ថលេខា ៖ -----------------------------

**ប្រធានក្រុមអាជ្ញាកណ្ដាល**

ឈ្មោះ ៖ **ម៉ែន ប៊ុនឈា**

ហត្ថលេខា ៖ -----------------------------

ក្រុមប្រឹក្សាអាជ្ញាកណ្ដាល THE ARBITRATION COUNCIL